# ការសំភាសន៍របស់អ្នកមីង អន ហ៊ាង

កៈ  អ្នកដែរសំភាសន៍គេមាន ជាងស៊ីអ៊ារ          ខៈ  អ្នកដែរអោយគេសំភាសន៍ អនហ៊ាង

## <u>ការសង្ខេបប្រវត្តិរបស់អ្នកមីង អន ហ៊ាង</u>

អ្នកមីង អន ហ៊ាង មានអាយុ55ឆ្នាំនៅក្នុងឆ្នាំ2018 អ្នកមីង អន ហ៊ាង មានភេទស្រី អ្នកមីង អន ហ៊ាង មានទីលំនៅបច្ចុប្បន្ននៅភូមិបឹងកំប្លោក សង្កាត់ចាក់អង្រែលើ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ។

កៈ  ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនមីងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់មីង ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយ នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍មីងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសមីង ចឹងតើមីងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេមីង?

ខៈ  អត់អីទេអូននិយាយមក

កៈ  ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍មីងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី21 ខែ3 ឆ្នាំ2018 ហើយធ្វើនៅនឹងភូមិអីគេដែរមីង?

ខៈ  នឹងគេហៅភូមិបឹងកំប្លោក

កៈ  ភូមិបឹងកំប្លោក ចុះឃុំអីគេដែរទៅមីង?

ខៈ  នៅឃុំអីគេទៅនេះឃុំដូចជាអត់សូវចាំទេ

កៈ  ចឹងអត់សូវចាំទេណាមីង ប៉ុន្តែដឹងតែសង្កាត់ចាក់អង្រែលើ?

ខ៖ ចាំ!នៅសង្កាត់ចាក់អង្រែលើ នៅភូមិបឹងកំប្លោក

ក៖ ប៉ុន្តែខ័ណ្ឌចំការមក?

ខ៖ ចាំ!នៅខ័ណ្ឌចំការមននឹង

ក៖ នៅរាជធានីភ្នំពេញនឹង ចឹងសំរាប់មីងឈ្មោះពេញរបស់មីងនឹងមានឈ្មោះអីគេដែរមីង?

ខ៖ ខ្ញុំនឹងឈ្មោះអន ហ៊ាង

ក៖ ឈ្មោះអន ហ៊ាង ចុះមានឈ្មោះហៅក្រៅទេមីង?

ខ៖ មានឈ្មោះហៅក្រៅនឹងនៅតែឈ្មោះហ៊ាងៗៗចឹងដដែរនឹង

ក៖ ឈ្មោះអន ហ៊ាងណាមីង?

ខ៖ ចាំ!អនហ៊ាងនឹងហើយ

ក៖ ចុះមីងកាលពីក្មេងនឹងមីងធ្លាប់មាននរណាហៅឈ្មោះមីងអីផ្សេងដែរទេមីង?

ខ៖ អត់មានទេ

ក៖ មានតែឈ្មោះមួយនឹងទេណាមីង?

ខ៖ មានឈ្មោះតាំងពីតូចរហូតមកដល់ចាស់ហើយនឹងហាស មានតែប៉ុណ្ណឹង

ក៖ ចុះមីងសព្វថ្ងៃនឹងមីងអាយុប៉ុន្មានដែរមីង?

ខ៖ ខ្ញុំអាយុ55ឆ្នាំហើយ

ក៖ មីងអាយុ55ឆ្នាំចុះមីងកើតនៅថ្ងៃខែឆ្នាំណាដែរមីងមានចងចាំទេ?

ខ៖ ខ្ញុំបានកើតនៅឆ្នាំ1960ប៉ុន្មានទេនេះខ្ញុំភ្លេចបាត់ហើយនឹងប៉ុន្តែនៅជំនាន់លុនណុល

ក៖ អូ៎!បាទមីង?

ខ៖ នៅទាន់លុនណុលរត់លូនផ្លោងខ្ញុំទាល់តែមើលអត្តសញ្ញាណប័ណនឹងបានខ្ញុំដឹង
យើងរវល់តែរកស៊ី នឹងចឹងយើងអត់ចងចាំហាស

ក៖ អូ៎!បាទមីងបាទអត់អីទេមីង ចឹងមីងកើតនៅឆ្នាំ1963មីង?

ខ៖  ចា៎!!!នឹងហើយ

ក៖  ចុះថ្ងៃខែមីងមានចងចាំទេមីង?

ខ៖  អត់ទេ

ក៖  មីងកើតនៅថ្ងៃអីខែអីក៏មីងអត់ចងចាំដែរណាមីង?

ខ៖  អត់ទេ

ក៖  ចុះដូចជាមីងកើតនៅណាវិញមីង?

ខ៖  ខ្ញុំនៅស្រុករបស់ខ្ញុំនឹងតែម្តងនឹងហាសស្រុកកំណើតកើតជានៅគៀនស្វាយតែម្តងនឹង

ក៖  ចុះនៅភូមិអី ឃុំអីដែរមីង?

ខ៖  នៅភូមិស្តៅកន្លែង

ក៖  ចុះឃុំវិញដែរមីង?

ខ៖  នៅឃុំដីឥដ្ឋ ភូមិស្តៅកន្លែង ស្រុកគៀនស្វាយ ខេត្តកណ្តាល

ក៖  អូ៎ៗបាទមីងចុះបើគិតជាឆ្នាំខ្មែរនឹងមីងឆ្នាំអីគេដែរមីង លក្ខណះថាឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខ៖  ខ្ញុំឆ្នាំថោះ

ក៖  ចឹងមីងឆ្នាំថោះណាមីង ចុះសំរាប់មីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរមីង?

ខ៖  ខ្ញុំមានបងប្អូន7នាក់

ក៖  ចុះមីងជាកូនទីប៉ុន្មានដែរទៅមីង?

ខ៖  ខ្ញុំជាកូនទី6

ក៖  បាទមីងចុះ មានស្រីប៉ុន្មាននាក់ ហើយនឹងស្រីប៉ុន្មាននាក់ដែរមីង?

ខ៖  ម៉ែរបស់ខ្ញុំនឹងមានប្រុស5នាក់ នឹងស្រី3នាក់

ក៖  នឹងបងប្អូនរបស់មីងហោសមីង?

ខ៖ ចាំ!ប៉ុន្តែស្លាប់បាត់អស់ហើយនឹងនៅតែពីរនាក់ទេស្រីៗនឹងហោស

ក៖ អូ៎!ចឹងមានន័យថាពួកគាត់ស្លាប់បាត់អស់ហើយណាមីង?

ខ៖ ចាំ!នឹងហើយនៅតែខ្ញុំនឹងហើយបងស្រីរបស់ខ្ញុំនឹង

ក៖ ប៉ុន្តែមានដឹងថាមូលហេតុអីបានជាគាត់ស្លាប់ដែរទេមីង?

ខ៖ គាត់មួយនោះកើតអេដស៍ មួយនោះបេះដូងរីក ខ្ញុំនឹងមហារីបំពង់ខ្យល់

ក៖ បាទមីងចុះបងប្អូនរបស់មីងនឹងគាត់មានឈ្មោះអីគេដែរទៅមីងមានចងចាំទេ?

ខ៖ ខ្ញុំនឹងបងប្អូនគេនឹងឈ្មោះបងម៉ន

ក៖ ចុះបងទី2វិញមីង?

ខ៖ នឹងទី1 ចំណែកទី2វិញនឹងឈ្មោះបង ថន

ក៖ ចុះបងទី3វិញមីង?

ខ៖ ទី3នឹងមានឈ្មោះបង ខន ទី4នឹងឈ្មោះបង ធឿន

ក៖ ចុះមីងទីប៉ុន្មានដែរមីង?

ខ៖ ខ្ញុំទី5នឹងច្រឡំនឹង

ក៖ ចុះទី6វិញដែរមីង?

ខ៖ ទី6នឹងពៅគេបានស្លាប់បាត់ទៅហើយនឹង

ក៖ ប៉ុន្តែគាត់មានឈ្មោះអីគេដែរមីង?

ខ៖ គេនឹងមានឈ្មោះអន ពៅដែរនឹង

ក៖ ចឹងមីងឈ្មោះអន ពៅដែរហោសមីង?

ខ៖ ខ្ញុំអត់ទេនឹងខ្ញុំឈ្មោះអន ហ៊ាង

កៈ មីងឈ្មោះអន ហ៊ាង
ចឹងមីងមានចងចាំថាកាលពីនៅក្មេងនឹងមីងមានធ្លប់បានលេងអីជាមួយបងប្អូនរបស់មីងដែរទេកាលនៅក្មេងៗហាសមីង?

ខៈ ខ្ញុំលេងផ្ទាត់កៅស៊ូនឹង

កៈ មីងលេងផ្ទាត់កៅស៊ូ ប៉ុន្តែមីងធ្លាប់លេងឡឹកបាយឡ លេងគប់ឈូសអីទេ?

ខៈ លេងផ្ទាត់កៅស៊ូ នឹងលេងបាយខំយកខ្ចៅធ្វើជាបាយខំនឹង

កៈ បាទមីងចុះលេងបិទពួនអីនឹងមីងមានធ្លាប់លេងទេ?

ខៈ លេងបិទពួននឹងលេងស្វាដណ្តើមទី

កៈ អូ!បាទមីង ចុះមីងមានធ្លាប់ទៅលេងអីនៅស្រែដែរជាមួយបងប្អូនរបស់មីងអត់?

ខៈ អត់ដែរមានបងប្អូននៅស្រែផងនឹង

កៈ ប៉ុន្តែដែរមានទៅដើរលេងអីជាមួយបងប្អូនរបស់មីងនៅស្រែដែរទេ?

ខៈ ខ្ញុំអត់ដែរសោះនឹង

កៈ ចឹងអត់ទេណាមីង
ចុះចឹងបងរបស់មីងដែរគាត់រស់នៅនឹងឥឡូវនឹងគាត់នៅណាវិញមីង?

ខៈ គាត់នៅស្រុកគៀនស្វាយ ខេត្តកណ្តាលដែរនឹង

កៈ អូ!បាទមីងបាទ?

ខៈ គាត់នៅស្រុកណុង

កៈ ប៉ុន្តែដូចជាគាត់ធ្វើអីគេដែរមីងឥឡូវនឹងហាសមីង?

ខៈ គាត់ធ្វើជាប្រធានភូមិនឹង

កៈ អូ!គាត់ប្រុសហោសមីង?

ខៈ ចា៎!គាត់ប្រុស

កៈ បាទមីងចុះម្តាយរបស់មីងនឹងគាត់មានឈ្មោះអីគេដែរមីង?

ខ៖ គាត់ឈ្មោះជា ខៅ

ក៖ ចុះគាត់អាយុប៉ុន្មានដែរមីង?

ខ៖ អូ៎!គាត់ស្លាប់បាត់ហើយនឹងកាលពីគាត់ស្លាប់នឹងមានអាយុ88ឆ្នាំ

ក៖ គាត់អាយុ88ឆ្នាំប៉ុន្តែគាត់ស្លាប់ប៉ុន្មានឆ្នាំដែរហើយមីង?

ខ៖ គាត់ស្លាប់នឹងចូល5-6ឆ្នាំហើយនឹង

ក៖ អូ៎ៗ!ចឹងមានន័យថាគាត់អាយុជាងកៅហើយណាមីង?

ខ៖ ចា៎!នឹងហើយ

ក៖ ចុះគាត់កើតនៅណាដែរមីងមានដឹងអត?

ខ៖ គាត់កើតនឹងស្រុកកំណើតរបស់គាត់នឹងនៅណុងតែម្តងនឹង

ក៖ គាត់នៅស្រុកគៀនស្វាយនឹងតែម្តងហោសមីង?

ខ៖ ចា៎!គាត់កើតនៅស្តៅកន្លែងនឹងឪពុករបស់ខ្ញុំ គាត់នៅស្តៅ ហើយម្តាយរបស់ខ្ញុំនឹងនៅភូមិកន្លែង

ក៖ ប៉ុន្តែដូចជាឪពុករបស់មីងនឹងគាត់មានឈ្មោះអីគេដែរមីង?

ខ៖ គាត់ឈ្មោះអន ចន

ក៖ គាត់ឈ្មោះអន ចនប៉ុន្តែគាត់អាយុប៉ុន្មានដែរមីង?

ខ៖ ឪពុករបស់ខ្ញុំនឹងកាលពីគាត់ស្លាប់នឹងគាត់អាយុហុកជាងហើយនឹង

ក៖ ប៉ុន្តែគាត់បងម្តាយមីងប៉ុន្មានឆ្នាំដែរទៅមីង?

ខ៖ គាត់អាយុដំណើរគ្នានិយាយរួមទៅ

ក៖ ចឹងគាត់អាយុដំណើរគ្នាហោសបង?

ខ៖ ចា៎!គាត់ឆ្នាំថោះដូចតែគ្នានឹង

ក៖ អូ៎!បាទមឹង
ចុះកាលពីឪពុករបស់មីងនឹងនៅរស់គាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខ៖ កាលពីជំនាន់លុនណុលនឹងគាត់ធ្វើជាកាម៉ង់ដូគាត់មានសាក់5

ក៖ អូ៎!គាត់ឡូយហាសមីង ចុះកាលពីគាត់នៅក្មេងនឹងគាត់ធ្វើអីគេដែរមីង?

ខ៖ ចា៎!ពេលដែរខ្ញុំដឹងក្តីនឹងមកខ្ញុំដឹងថាពុករបស់ខ្ញុំនឹងគាត់ធ្វើជាកាម៉ង់ដូនឹង

ក៖ អូ៎!បាទបងបាទ?

ខ៖
គាត់អោយហៅប៉ាៗៗខ្ញុំអត់ទំលាប់ផងនឹងខ្ញុំទំលាប់ហៅតែពុកៗៗនឹងនៅជំនាន់អាពតនឹង បើសិនជា ហៅប៉ានឹងស្លាប់បាត់ហើយនឹង

ក៖ គេថាខ្មែរចិនមែនទេមីង?

ខ៖ ចា៎!គេថាចិននឹង

ក៖ អូ៎!ម៉េចចឹងមីង?

ខ៖
គេហៅខ្ញុំទៅសួរដែរនឹងគាត់សួរថាប៉ាហែងធ្វើអីហើយខ្ញុំប្រាប់ថាទេពុករបស់ខ្ញុំនឹងធ្វើស្រែ នឹងធ្វើស្រូវនឹងពីព្រោះពុករបស់ខ្ញុំនឹងគាត់អោយលាក់ បើមិនលាក់នឹងពុករបស់ខ្ញុំនឹងស្លាប់ នៅជំនាន់អាពតបាត់ហើយនេះ

ក៖ មីងដែរហោសមីង?

ខ៖ ចា៎!ប៉ុន្តែខ្ញុំលាក់ ពុកខ្ញុំប្រាប់ថាកុំអោយប្រាប់ថាពុកធ្វើកាម៉ង់ដូសាក់5អី ពេលសួរនឹងប្រាប់ថាធ្វើស្រែ នឹងធ្វើស្រូវទៅនឹង

ក៖ អូ៎!ចឹងហោសមីងបាទ?

ខ៖ តែចឹងទេគេយកពុកទៅវៃចោលហើយនឹង

កៈ
ហេតុអីបានជាខាងពលពតគេមិនអោយហៅប៉ាហើយហេតុអីបានជាគេចង់សំលាប់ចិនចឹងមីង?

ខៈ អត់ដឹងអីផងអូនយតែហៅប៉ាទៅគេថាយើងធ្វើធំចឹងគេយកទៅសំលាប់ចោលនឹង

កៈ អ្ហ៎!ចឹងទេហោសមីង គេថាចិនពួកអ្នកធ្វើធំហោសមីង?

ខៈ ចា៎!នឹងហើយតែយើងហៅពុកធ្វើស្រែនឹងធ្វើស្រូវទៅរស់បានយូរដែរ

កៈ បាទមីងចុះឪពុករបស់មីងនឹងគាត់ស្លូតរឺមួយកាចដែរមីង?

ខៈ ឪពុករបស់ខ្ញុំនឹងគាត់ស្លូតនឹង

កៈ ចឹងគាត់ស្លូតទេណាមីង?

ខៈ ហើយម៉ែរបស់ខ្ញុំនឹងគាត់ក៏ស្លូតដែរនឹង

កៈ បាទមីង ចុះប៉ុន្តែម្តាយរបស់មីងនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខៈ ម្តាយរបស់ខ្ញុំនឹងគាត់លក់ដូរដូចខ្ញុំសព្វថ្ងៃចឹងដែរនឹង ប៉ុន្តែគាត់ទៅលក់នៅកន្លែងហើយគាត់មានតូបមួយនឹង

កៈ ប៉ុន្តែឥឡូវនឹងគាត់នៅរស់រឺមួយក៏?

ខៈ គាត់ស្លាប់បាត់ទាំងពីរនឹង

កៈ ប៉ុន្តែកាលពីមុនណាមីង?

ខៈ ចា៎!នឹងហើយម៉ែរបស់ខ្ញុំនឹងគាត់ស្លាប់ក្រោយពុករបស់ខ្ញុំនឹងទេ

កៈ
ចុះមីងមានចងចាំសាច់រឿងអីជាមួយម្តាយឪពុករបស់មីងទេកាលពីមីងនៅក្មេងៗចឹងហាស មីងធ្លាប់ធ្វើអីគេខ្លះដែរជាមួយគាត់ដែរមីងចងចាំអនុស្សាវរីយ៍អត់ភ្លេចដែរទេ?

ខៈ ខ្ញុំជួយម៉ែរបស់ខ្ញុំនឹងលក់ដូរពេលដែរមកពីរៀនវិញនឹង ខ្ញុំជួយលក់ដូរគាត់

កៈ អ្ហ៎ៗ!បាទមីងបាទ?

ខ៖  ជួយពេលដែរមកពីរៀនវិញយកសៀវភៅនឹងទំលាក់ចូល
រៀនលក់ជាមួយគាត់អីចឹងទៅ មានជាបន្លែ នឹងផ្លែឈើជាមួយគាត់ចឹងទៅ

ក៖  បាទមីងបាទ?

ខ៖
ហើយចេញពីចឹងទៅញុំាបាយញុំាអីហើយនឹងទៅរៀនទៅពេលដែរចេញពីរៀនវិញមកនឹងក៏រៀបចំជួយលក់ឥវ៉ាន់ម្តាយចឹងទៅ

ក៖  អូ៎!បាទចឹងណាមីង?

ខ៖  ផាគតិចណាស់បានទៅលេងគប់វង្ស ពេលដែរខ្ញុំទំនេរថ្ងៃអាទិត្យទេនឹង

ក៖  អូ៎!ចឹងមានន័យថាគាត់ទំនេរថ្ងៃអាទិត្យនឹងបានគាត់អោយលេងណាមីង?

ខ៖  ចា៎!និយាយទៅគាត់ទំលាប់អោយកូនល្អតែម្តងនឹងហាស

ក៖  ចុះថ្ងៃធម្មតានឹងគាត់អោយទៅរៀន?

ខ៖  ចា៎!!នឹងហើយ

ក៖  អូ៎!បាទមីង
ចុះម្តាយរបស់មីងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់កាលពីគាត់នៅក្មេងទៅមីងទេ?

ខ៖  គាត់ប្រវត្តិរបស់គាត់នឹងគាត់ថាគាត់ពិបាកវេទនានឹង
គាត់អត់ដូចក្មេងសម័យឥឡូវនឹងចឹងហាស គាត់នៅជាមួយម្តាយរបស់គាត់នឹងគាត់ធ្វើស្រែនឹងធ្វើស្រូវនឹង ហើយងើបពីព្រឹកម៉ោង5-6អីចឹងគាត់ ទៅបុកអង្ករអីចឹងហាស

ក៖  បាទមីងបាទ?

ខ៖  នៅធ្វើស្រែនឹងធ្វើស្រូវចឹងទៅ

ក៖  ប៉ុន្តែនឹងកាលពីគាត់នៅក្មេងៗមែនទេមីង?

ខ៖  ចា៎!!កាលពីគាត់នៅមិនទាន់មានប្តីមានអីចឹងហាស

ក៖  ប៉ុន្តែនៅពេលដែរគាត់មានប្តីនឹងគាត់ធ្វើអីគេដែរទៅមីង?

ខ៖  គាត់មានប្ដីមានអីចឹងទៅឪពុករបស់ខ្ញុំនឹងគាត់ធ្វើជាកាម៉ង់ដូចឹងម៉ែរបស់ខ្ញុំនឹង
គាត់លក់ឥវ៉ាន់ចាប់ហ៊ួយអីចឹងទៅ នឹងលក់ផ្លែឈើអីចឹងទៅដូចជាផ្លែសៅម៉ៅអីចឹងហាស

ក៖
បាទមីងចុះឪពុករបស់មីងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់កាលពីនៅក្មេងនឹងទៅមីងដែរទេ?

ខ៖  គាត់កាលពីក្មេងនឹងគាត់រៀនសូត្រគាត់បានទៅស្រុកយួនស្រុកអីចឹងដែរនឹងហាស

ក៖  អូ៎!ចឹងគាត់ធ្លាប់ទៅរស់នៅស្រុកយួនដែរហោសមីង?

ខ៖  ចា៎!!ថាគាត់ធ្លាប់ទៅរៀននៅស្រុកយួនអីចឹង

ក៖  គេរៀនអីគេវិញដែរនៅស្រុកយួន?

ខ៖  គាត់រៀនកាលពីជំនាន់លុនណុលនឹងគាត់លឺថាគេអោយទៅរៀនចឹងទៅ
មិនដឹងថារៀនពីមូលហេតុ អីផងនឹង បែបរៀនភាសាវៀតណាមក៏មិនដឹង
ឃើមើវិញនឹងគាត់ចេះវៀតណាមនឹង

ក៖  អូ៎!គាត់ចេះវៀតណាមច្រើនហោសមីង?

ខ៖  ចា៎!!នឹងហើយ

ក៖  បាទមីង ចុះយាយតាខាងឪពុកនឹងមីងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖  យាយរបស់ខ្ញុំនឹងនៅខាងម៉ែរបស់ខ្ញុំនឹងឈ្មោះយាយស្រី នឹងតាគា

ក៖  នឹងខាងម្ដាយណាមីង?

ខ៖  ចំណែកខាងឪពុករបស់ខ្ញុំនឹងឈ្មោះយាយអន នឹងតាអែម

ក៖  ប៉ុន្តែមីងមានដឹងថាយាយតាខាងម្ដាយនឹងគាត់កើតនៅណាដែរទេមីង?

ខ៖  កើតស្រុកកំណើតរបស់គាត់នឹងនៅណុងតែម្ដងនឹង

ក៖  នៅគៀនស្វាយនឹងតែម្ដង?

ខ៖  ចា៎!!កំណើតកើតជានឹងនៅនឹងតែម្ដងនឹង

កៈ ចុះយាយតាខាងឪពុកនឹងមីងមានដឹងថាគាត់កើតនៅណាដែរទេមីង?

ខៈ គាត់កើតនៅស្តៅនឹងដែរឪពុករបស់ខ្ញុំនឹង

កៈ អូ៎!!ប៉ុន្តែនៅគៀនស្វាយនឹងដែរណាមីង?

ខៈ ចាំ!ស្រុកកំណើតនៅជាមួយគ្នានឹង

កៈ បាទចុះមីងមកនៅទីក្រុងភ្នំពេញនឹងយូរនៅមីង?

ខៈ ខ្ញុំមកនៅអស់រយះពេល4ឆ្នាំហើយអូន

កៈ ចឹងមីងនៅអស់រយះពេល4ឆ្នាំហើយណាមីង?

ខៈ ចាំ!នឹងហើយ

កៈ បាទចុះមីងមានបងប្អូនរឺមួយក៏សាច់ញាតិណាដែរគាត់ទៅរស់នៅក្រៅប្រទេសទេមីង?

ខៈ អត់មានទេមានតែបងប្អូននៅខាងប្តីរបស់ខ្ញុំនឹង

កៈ គាត់នៅណាវិញមីង?

ខៈ នៅអូស្រ្តាលី

កៈ អូ៎!ចុះគាត់ធ្វើអីគេដែរនៅណុងហាសមីង?

ខៈ គាត់នឹងអាត្រេតហើយឥឡូវនឹងហោស
ពីមុនគាត់ធ្វើការប៉ុន្តែឥឡូវនឹងគាត់អាត្រេតហើយនឹង

កៈ ប៉ុន្តែគាត់ទៅនៅជាមួយកូនចៅរបស់គាត់ទាំងអស់តែម្តងហោសមីង?

ខៈ គាត់នៅជាក្រុមគ្រួសាររបស់គាត់នឹង

កៈ អូ៎!កូនចៅរបស់គាត់ធានាគាត់ទៅហោសមីង?

ខៈ ចាំ!និយាយទៅគាត់នៅណុងយូរហើយនឹង
គាត់ទៅនៅទាំងយាយទាំងតាកាលពីជំនាន់អាពត គាត់បានសំភាសន៍ទៅហាស

កៈ បាទមីងបាទ?

ខ៖ ចេះតែរត់ទៅៗៗទៅនឹងគេទៅចេះតែរត់ទៅនៅជាមួយនឹងគេនឹងឯងចឹងទៅ

ក៖ អូ៎!ពេលណុងគេអោយទៅនៅfreeណាមីង?

ខ៖ ចា៎!!

ក៖ ចឹងគេអោយទៅនៅស្រួលៗៗនឹង ចុះស្វាមីរបស់មីងនឹងឈ្មោះអីគេដែរមីង?

ខ៖ ប្តីរបស់ខ្ញុំនឹងគាត់មានឈ្មោះជា សៅ

ក៖ ចុះមីងមានចងចាំថ្ងៃដែរមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយពូទេ?

ខ៖ អើរកាលណុងខ្ញុំការនឹងនៅឆ្នាំ1981

ក៖ នៅឆ្នាំ1981ប៉ុន្តែថ្ងៃខែនឹងមីងអត់ចងចាំទេ?

ខ៖ អត់ចងចាំទេ

ក៖
អូ៎!បាទចុះនៅពេលដែរមីងរៀបអាពាហ៍ពិពាហ៍ជាមួយពូនឹងគិតថាមីងជាអ្នករៀបចំដោយចិត្តឯងរឺ មួយក៏ឪពុកម្តាយរបស់មីងគាត់ជាអ្នករៀបចំអោយដែរមីង?

ខ៖ ឪពុកម្តាយគាត់អ្នកគូរផ្គងអោយហាស អត់ដែរស្គាល់គ្នាផងនឹង

ក៖ អូ៎!បាទចឹងពេលដែរការនឹងមានជាថ្លៃជំនូនអត់មីង?

ខ៖ ចា៎!!!ថាម៉េច?

ក៖ មានជាថ្លៃជំនូនជូនទៅមីងអត់មីង?

ខ៖ ជូនដែរកាលណុងប៉ុន្មានទេដូចជា3ជីមាសនឹង

ក៖ មាន3ជីចុះកាលណុងលុយថ្លៃទេមីង?

ខ៖ ពេលណុងមួយជីនឹង7ពាន់លុយខ្មែរនឹង

ក៖ ប៉ុន្តែថ្លៃអត់កាលណុងលុយហាសមីង?

ខ៖ វាថ្លៃនៅប្រើកាក់ នៅប្រើលុយដុងនៅឡើយនឹង

កៈ ប៉ុន្តែ?

ខៈ នៅឆ្នាំ1981នឹងនៅប្រើលុយដុងនៅឡើយទេនឹង

កៈ ប៉ុន្តែមាសថោកមែនទេមីង?

ខៈ មាសនឹងថោកមាសកាលណុងនៅសល់មាសមួយជី ស្មើរ70រៀលនឹងខ្ញុំនៅចងចាំ

កៈ ប៉ុន្តែមីងគិតថាមីងដែរជួបប្តីរបស់មីងនឹងពីមុននឹងរៀបការអត់?

ខៈ អត់ដែរទេអត់ដែរស្គាល់គ្នាផងនឹង

កៈ មកដល់ឪពុកម្តាយគាត់រៀបចំអោយតែម្តងហោស?

ខៈ អោយលុយគេទៅមើលឃើញចរឹកចឹងគេនាំមកហាស

កៈ បាទមីងបាទ?

ខៈ ចូលស្ដីរចាស់ទុំនឹងអត់ដែរស្គាល់គ្នាពីមុនចឹង

កៈ ចុះមីងមានចេះអីគេក្រៅភាសាខ្មែរទេមីង?

ខៈ ខ្ញុំអត់សូវចេះផងខ្មែរមិនសូវចេះអក្សរផងនឹង

កៈ ចុះវៀតណាម ថៃ ចិនអីក៏មីងមិនចេះដែរ?

ខៈ អត់អត់ចេះសោះតែម្តងនឹង

កៈ ចុះមីងធ្លាប់បានរៀនទេមីង?

ខៈ ខ្ញុំរៀនបានត្រឹមថ្នាក់ទី3ហោស

កៈ ប៉ុន្តែកាលមីងរៀននឹង?

ខៈ ប៉ុន្តែកាលពីជំនាន់ណុងរត់លូនៗៗគ្មានសូវបានរៀនទេ

កៈ អូ!ចឹងហោសមីង?

ខៈ បាទរៀនតែបេសកម្ម

កៈ អូ!ប៉ុន្តែកាលពីមីងរៀននឹងមីងរៀននៅណាដែរមីង?

ខ៖ ខ្ញុំរៀននៅស្តៅកន្លែងនឹងនៅស្រុកខ្ញុំនឹង

ក៖ ប៉ុន្តែសាលាឈ្មោះអីគេដែរមីង?

ខ៖ សាលាឈ្មោះសាលាស្តៅកន្លែង

ក៖ សាលាស្តៅកន្លែង?

ខ៖ មិនសូវបានរៀនទេអូនអើយរត់លូនៗៗរហូតនឹង

ក៖ បាទមីងបាទចុះ?

ខ៖ បើបានរៀនជាប់នឹងក៏ពូកែដែរនឹង

ក៖ បាទចុះមីងធ្លាប់មានមិត្តភក្តិដែរស្និទ្ធតិស្នាលធំធាត់មកជាមួយគ្នាដែរទេមីង?

ខ៖ អត់ដែរមានទេខ្ញុំតាំងពីក្រមុំនឹងមកមិនដែរចេះមានពយកម៉ាក់ទេនឹង

ក៖ ចុះកាលពិនៅក្មេងៗៗវិញមីង?

ខ៖ កាលនៅក្មេងៗៗនឹងខ្ញុំដើរតែម្នាក់ឯងៗៗនឹង

ក៖ ចុះកាលនៅក្មេងនឹងមីង?

ខ៖ នៅក្មេងចឹងដែរអូន?

ក៖ អត់ដែរមានទេណាមីង?

ខ៖ ចាំ!!មានតែក្មេងៗៗនៅក្នុងសាលាចឹងទៅចេញពីក្នុងសាលាចឹងអត់ដែរមានទេ

ក៖ អ៎ូ!បាទមីង ចុះមីងធ្លាប់ទៅធ្វើការងារនៅវាលស្រែទេមីង?

ខ៖ ខ្ញុំទៅស្ទូង នឹងទៅដក់ជាមួយម៉ែរបស់ខ្ញុំនឹង

ក៖ មួយនឹងគ្រាន់តែមីងទៅស្ទូងនឹងទៅដកទេណាមីង អត់មានទៅធ្វើអីទៀតទេណាមីង?

ខ៖ អត់ទេ

ក៖ បាទមីងចុះមីងធ្លាប់បើកអាជីវកម្មលក់ដូរអីទេមីង?

ខ៖ ខ្ញុំតាំងពីក្មេងនឹងមកលក់រហូតនឹងលក់ជាមួយម៉ែរបស់ខ្ញុំនឹង

កៈ មានលក់អីគេខ្លះដែរទៅមីង?

ខៈ ម៉ែរបស់ខ្ញុំនឹងគាត់មានលក់ផ្លែឈើអីចឹងហាស

កៈ អូ៎!បាទមីងបាទ?

ខៈ ដល់ពេលដែរខ្ញុំមានប្តីនឹងខ្ញុំចាប់មុខរបរនឹងជាប់រហូតនឹង

កៈ មីងលក់បបរទៅ?

ខៈ តាំងពីនៅស្រុកហោស

កៈ ប៉ុន្តែមីងលក់បបរមែនទេមីង?

ខៈ ចា៎!!ចិញ្ចឹមកូននឹងចិញ្ចឹមចៅ7នាក់

កៈ អូ៎!បាទមីងបាទ?

ខៈ រហូតដល់ឥឡូវនឹងហាស

កៈ ចុះមីងធ្លាប់ចិញ្ចឹមមាន់ ចិញ្ចឹមទា ជ្រូក គោ ក្របីអីទេមីង?

ខៈ ខ្ញុំចិញ្ចឹមគោ ចិញ្ចឹមជ្រូក ដល់ពេលជ្រូកខាតអស់500$ទៅក៏ឈប់ទៅ

កៈ អូ៎!ប៉ុន្តែមីងចិញ្ចឹមច្រើនរឺមួយក៏ចិញ្ចឹមតិចដែរមីង?

ខៈ ខ្ញុំចិញ្ចឹមច្រើនជ្រូកពូជគេនឹង

កៈ ប៉ុន្តែចិញ្ចឹមលក្ខណៈជាកសិដ្ឋានណាមីង?

ខៈ អត់ទេចិញ្ចឹមលក្ខណៈនៅស្រុកយើងតែម្តងនឹង ខ្ញុំចិញ្ចឹមធ្វើជាឯកជនតែម្តងនឹងហាស

កៈ ចឹងជាលក្ខណៈគ្រួសារមែនទេមីង?

ខៈ ចា៎!!នឹងហើយគោរបស់ខ្ញុំនឹងមាន3-4ក្បាលនឹងដល់ដែរខ្ញុំចេញពីស្រុកនឹងខ្ញុំលក់អស់ហើយនឹង

កៈ ចុះមីងគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះនឹងតើមីងធ្លាប់ធ្វើការងារអីគេខ្លះដែរនៅក្នុងជីវិតរបស់ មីងដែរទៅ?

ខ៖ ខ្ញុំជីវិតរបស់ខ្ញុំនឹងតែលក់ដូរនឹង

ក៖ ចឹងមានន័យថាលក់តែដូរទេណាមីង?

ខ៖ ចា៎!!នឹងហើយ

ក៖ នឹងធ្វើស្រែចំការណាមីង?

ខ៖ ចា៎!!!

ក៖ បាទមីង ចុះមីងគិតថាជីវិតរបស់មីងនឹងមានការផ្លាស់ប្តូរអីគេខ្លះដែរមីង?

ខ៖ អត់ផងនឹង

ក៖ អត់មានការផ្លាស់ប្តូរអីទេ ចុះជីវភាពឥឡូវនឹងយ៉ាងម៉េចដែរមីង?

ខ៖ អើយពិបាកណាស់អូនអើយនៅស្រុកខ្មែរហោស

ក៖ បាទមីងបាទ?

ខ៖ យ៉ាប់ហាសរកតែមួយកែបានមួយកែទេនឹង

ក៖ អូ៎!បាទមីងចុះ?

ខ៖ បើអោយចំណេញនឹងវាចំណេញហើយរកអោយតែថ្លៃផ្ទះ ថ្លៃទឹក ថ្លៃភ្លើងនឹង

ក៖ អស់បាត់ទៅហើយ?

ខ៖ ចា៎!ហើយយកលុយអង្គការគេទៀតខ្ញុំនឹង យកមកធ្វើផ្ទះនៅស្រុកហោស

ក៖ បាទមីងប៉ុន្តែមីងបានធ្វើផ្ទះហើយហើយណាមីង?

ខ៖ ហើយៗនឹង

ក៖ ចុះមីងគិតថាសុខភាពរបស់មីងនឹងឥឡូវនឹងយ៉ាងម៉េចដែរមីង?

ខ៖ មួយថ្ងៃឈឺ មួយថ្ងៃកាត់មួយថ្ងៃកោរដែរនឹងអូនអើយ

ក៖ ចឹងហោសមីង?

ខ៖  ប៉ុន្តែចេះតែប្រឹងទៅនឹង
បើយើងមិនប្រឹងនឹងមាននរណាគេជួយយើងបើកូនបែកគ្រួសារទៅអស់
ទៅចិញ្ចឹមប្រពន្ធចិញ្ចឹមកូនគេអស់ហើយនឹង

ក៖  បាទមីងបាទ ចុះមីងចូលចិត្តពិសារម្ហូបអីគេដែរមីង?

ខ៖  ខ្ញុំហោសម្ហូបសំលយើងធម្មតានឹងសំលសាមញ្ញៗៗនឹង

ក៖  លក្ខណះស្ងោរ ឆា ចៀន ម្ជូរនឹង?

ខ៖ ចាំ!!តែប៉ុណ្ណឹងឯងនឹង

ក៖  ប៉ុណ្ណឹងណាមីង ចុះកក្ធូរ ការីអីមីងចូលចិត្តទេ?

ខ៖  ចូលចិត្តប៉ុន្តែអត់មានពេលហូបផងគ្មានពេលស្លនឹង

ក៖  ចុះមីងគិតថាតាំងពីក្មេងនឹងល្បែងប្រជាប្រិយ៍អីដែរមីងចូលចិត្តលេងដែរមីង?

ខ៖  ខ្ញុំចូលចិត្តបោះឈូង បោះអង្គុញ ហើយនឹងលោតអន្ទាក់

ក៖  ចុះលាក់កន្សែងអីមីង?

ខ៖  លេងឈូស គប់វង្ស

ក៖  ចុះលាក់កន្សែង ចាប់កូនខ្លែងអីមីងចូលចិត្តលេងដែរតើហីមីង?

ខ៖  អើរលេងចាប់តែស្លឹកឈើនឹង

ក៖  អូ៎!លេងដណ្តើមស្លឹកឈើហីមីង?

ខ៖  ចាំ!!លេងដណ្តើមស្លឹកឈើ ស្វាដណ្តើមទី

ក៖  អូ៎!បាទមីង ចុះមីងគិតថាមីងចេះច្រៀងដែរទេមីង?

ខ៖  អត់ចេះច្រៀងទេអូនអើយ

ក៖  អត់ចេះទេប៉ុន្តែមីងចូលចិត្តស្តាប់បទចំរៀងទេមីង?

ខ៖  ស្តាប់បទចំរៀងយើងខ្មែរយើងពីដើមនឹងចេះស្តាប់មកសង្គមនេះអត់ចេះទេ

កៈ ប៉ុន្តែយីកេអោយែអីមីងចេះអត់ចូលចិត្តស្តាប់អត់មីង?

ខៈ ខ្ញុំចូលចិត្តដែរនឹង

កៈ ចូលចិត្តណាមីង?

ខៈ អោយតែខ្មែរបុរាណ

កៈ
ចុះមីងគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសាររបស់មីងនឹងចេះលេងឧបករណ៍ភ្លេងដែរទេមីង?

ខៈ អត់ផងអូន

កៈ អត់មានទេណាមីង?

ខៈ ចាំ!!អត់មានទេ

កៈ
ចុះផ្ទះរបស់មីងនឹងមានលក្ខណៈបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាសមីង?

ខៈ ផ្ទះរបស់ខ្ញុំនឹងហោសផ្ទះធម្មតានឹង

កៈ អូ៎!ផ្ទះឈើធម្មតាទេហោសមីង ប៉ុន្តែផ្ទះមួយនឹងនរណាគេជាអ្នកសាងសងដែរមីង?

ខៈ និយាយរួមទៅផ្ទះនឹងគឺផ្ទះកូននឹង កូននៅលីវនឹង

កៈ អូ៎!បាទប៉ុន្តែចង់និយាយថាមីងជួលគេធ្វើរឺមីងធ្វើដោយខ្លួនឯង?

ខៈ យើងជួលគេនឹង

កៈ ប៉ុន្តែនៅក្នុងក្រុមគ្រួសាររបស់មីងនឹងអត់មាននរណាគេចេះធ្វើផ្ទះទេណាមីង?

ខៈ អត់មានទេ

កៈ អូ៎!បាទ ចុះមីងគិតថាផ្ទះរបស់មីងនឹងគេប្រើឧបករណ៍អីគេសំរាប់ធ្វើផ្ទះមួយនឹងទេមីង?

ខៈ មានឈើគ្រឿងឈើអីនឹងមានដូចជារណាអីចឹងទៅណាស់

កៈ បាទៗៗខ្ញុំចង់និយាយមួយនឹងហាសមីង?

ខៈ ចាំៗៗ!មានជារណា គេឈូសដៃ

កៈ មានដែកគោល?

ខៈ មានដូចជាដែកគោលនឹងអី

កៈ មានដែកឈូសមានអីទៅណាមីង?

ខៈ មានពន្លាក់ មានដែកដាប់នឹងផ្ទះឈើមានតែប៉ុណ្ណឹងឯង

កៈ មានដែកគាស់ដែរតើហីមីង?

ខៈ ដែកគាស់មានដែរតើនឹង

កៈ បាទមីងចុះមីងគិតថាជំនាញអីគេដែរមីងចេះស្ទាត់ជំនាញដែរមីង?

ខៈ ខ្ញុំចេះជាងគេនឹងបបរនឹងតែម្ដងនឹង

កៈ មានបបរណាមីងណា?

ខៈ មានបបរ មីគុយទាវអីចឹងទៅណាស់

កៈ ចុះម្ដាយឪពុករបស់មីងនឹងធ្លាប់បង្រៀនពីជំនាញអីទៅមីងដែរទេ?

ខៈ គាត់លក់តែផ្លែឈើទេម៉ែរបស់ខ្ញុំនឹង

កៈ ចឹងមានន័យថាគាត់បង្រៀនមីងអោយចេះលក់?

ខៈ ខ្ញុំអត់ទេមានកូននឹងចេះខ្លួនឯងតែម្ដងនឹង

កៈ អូ៎!បាទមីងចុះមីងគិតថា?

ខៈ ជីវភាពយើងអត់ហើយចេះតែរកមុខរបរចិញ្ចឹមកូនទៅនឹង

កៈ ចុះមីងគិតថាវេញវល្លិ៍ កូរស្ករ ធ្វើផ្ដៅអីមីងចេះទេ?

ខៈ អត់ចេះទេកូន

កៈ អូ៎!បាទមីង
ចុះមីងអាចប្រាប់ខ្ញុំពីពេលកាលដែរមីងនៅក្មេងបានទេមីងធ្លាប់ជួបការលំបាកអីគេខ្លះដែរទៅមីង?

ខៈ
អើរពិបាកណាស់អូនខ្ញុំកើតមកមួយជាតិនេះគ្មានពេលស្រណុកទេមានតែពេលពិបាកនឹងកើតមកចឹងមកចឹងទៅមានតែពិបាករត់លូននៅជំនាន់លុនណុល
ចេញពីជំនាន់លុនណុលនឹងរត់លូន
នឹងហើយក្រាបលូននឹងគេហៅថាក្មេងក្រោមគ្រាប់ផ្លោងហាស

កៈ បាទមីងបាទ?

ខៈ ចេញពីនឹងហើយពិបាកវេទនានឹងនៅជំនាន់អាពតនឹង

កៈ កាលពីជំនាន់ពលពតនឹងគេអោយមីងធ្វើអីគេដែរទៅ?

ខៈ អើរស្ទូង មានដកអូនអើយ

កៈ ប៉ុន្តែពេលណុងគេអោយមីងទៅណាដែរទៅជំលាសមីងទៅណាដែរទៅមីង?

ខៈ ពេលណុងគេជំលាសខ្ញុំទៅពោសាត់ បាត់ដំបងហោស

កៈ អូ៎!ប៉ុន្តែអោយយើងដើរទៅហោសមីង?

ខៈ អោយដើរទៅរហូតនឹងអូកាលណុងជិះអាមេរិនតាមទន្លេនឹងជូនយើងទៅហាស

កៈ បាទមីងបាទ?

ខៈ ដល់ពេលដែរទៅដល់ណុងទៅខ្ញុំទៅកាប់កន្ត្រាំងខែតកន្ត្រាំងអីចឹង
មានជីអាចម៍គោអាចម៍អីចឹង
កាលណាបើយើងអត់ទៅអត់ធ្វើចឹងគេវៃគេដុំយើងចឹងទៅណាស់

កៈ ប៉ុន្តែពេលណុងនៅអាយុប៉ុន្មានដែរមីង?

ខៈ ខ្ញុំកាលណុងនៅក្មេងដែរនឹងនៅជំទង់

កៈ ប៉ុន្តែប្រហែលជាអាយុ?

ខ៖ ប្រហែលជាអាយុខ្ទង់12-13ឆ្នាំនឹងកាលណុង

ក៖ អ៊ូ!ចឹងមីងនៅកងកុមារនៅឡើយដែរតើហីមីង?

ខ៖ ចា៎!!ដល់ពេលដែរខ្ញុំបែកជំនាន់អាពតនឹងមករៀតណាមរំដោះយកមកនឹងខ្ញុំអាយុ18ឆ្នាំ អាយុ19ឆ្នាំនឹងខ្ញុំបានការ

ក៖ ប៉ុន្តែមីងកាលពីជំនាន់ពលពតចឹងមីងនៅជាកងកុមារចឹងមីងគេអោយនៅជាមួយឪពុកម្តាយរឺ អត់មានទេមីង?

ខ៖ អត់មានទេនៅកងនឹងនៅកងអឺវ៉ាន់

ក៖ នៅកងកុមារនឹងតែម្តងហោសមីង?

ខ៖ ចា៎!!!នឹងហើយ

ក៖ ចុះឪពុកម្តាយរបស់មីងនឹងគេអោយទៅណាដែរទៅមីងពេលណុងមីង?

ខ៖ នៅផ្សេងៗពីគ្នានឹងនៅសហាករខុសគ្នានឹង

ក៖ អ៊ូ!បាទមីងបាទ?

ខ៖ ខ្ញុំនៅសហាករកុមារចឹងទៅអឺវ៉ាន់កងព្រលិតនឹងកងធំចឹងទៅ

ក៖ បាទមីងបាទ?

ខ៖ កងអឺវ៉ាន់នឹងគេហៅកងកូនក្មេងតូចៗចឹងហាសកងអឺវ៉ាន់នឹងហោស

ក៖ បាទមីងចុះរបបអាហារនឹងយ៉ាងម៉េចដែរមីង?

ខ៖ អូយវេទនាណាស់អូន

ក៖ ក្មេងក៏គេ?

ខ៖ អត់ដែរមានបាយហូបនឹងបបរហូបយ៉ាងម៉េចទេនឹងមួយថ្ងៃនឹងគ្រាប់សណ្តែកបាយយើងមួយ ស្លាបព្រាកាហ្វេទេអូន

ក៖ ស្លាប់ចុះបើយើង?

ខ៖ ហូបកន្ទួក

ក៖ ចុះយើងមានកំលាំងណាធ្វើការទៅមីង?

ខ៖ អ៊ូ!មិនដឹងយ៉ាងម៉េចទេអូនកាលពីជំនាន់ណុងចេះតែមានហើយនឹង

ក៖ ប៉ុន្តែចេះតែមានកំលាំងធ្វើការងារដែរទៅ?

ខ៖ ចាំ!!កាលណុងជំនាន់ណុងមានកន្ទួក មានហូបកន្ទួកហូបអីអោយចេះតែរស់ៗទៅនឹង មានដំឡូងឈើដំឡូងអីចឹងទៅ

ក៖ ចុះយើងឈឺធ្វើម៉េចទៅមីង?

ខ៖ ឈឺនឹងគេអាពេទ្យ

ក៖ គេមានពេទ្យគេដែរហីមីង?

ខ៖
ជំនាន់អាពតនឹងគេយកទឹកដូងយើងនឹងទៅបាញ់ដាក់សារាំងនឹងទៅចាក់អោយយើងនឹង

ក៖ អ៊ូ!!!បាទមីង?

ខ៖ ដូងនឹងទាំងផ្លែទាំងផ្កាយៗនឹង

ក៖ បាទមីងនបាទនឹង?

ខ៖
វេទនាណាស់អូនអើយនៅជំនាន់អាពតនឹងហោសក្មេងឥឡូវនឹងទោះប្រាប់ក៏វាមិនសូវចេះជឿងយើង ដែរនឹង

ក៖ បាទមីងបាទ?

ខ៖ គិតទៅកើតមកនឹងធ្លាប់ពិបាករហូតនឹងតែម្តងនឹង

ក៖ អ៊ូ!បាទមីង?

ខ៖
អត់ដែរបានរៀនសូត្រអីទេរៀនបានតែបន្តិចនឹងជំនាន់លុណនុលនឹងគេវៃជុំរត់គ្រាប់ផ្លោងចឹងទៅ

ក៖ ប៉ុន្តែយើងចេះតែរត់រហូតចឹងទៅណាមីង?

ខ៖
ចាំ!!!ដល់ពេលដែរចេញពីនឹងទៅជំនាន់អាពតនឹងមើលទៅកើតមកមួយជាតិនឹងមិនដែរបានស្រណុក តែម្តងនឹងអូនពិបាករហូតនឹង

ក៖ អូំ!រហូតដល់ពេលណាដែរបានយើងអាចជួបឪពុកម្តាយរបស់យើងវិញទៅមីង?

ខ៖ ទាល់តែវៀតណាម

ក៖ ទាល់តែដាច់តែម្តងនឹងនិយាយរួមនឹង?

ខ៖
វៀតណាមគេរំដោះមកចឹងទៅបានទៅជួបឪពុកម្តាយរហូតទាល់តែគាត់បានរៀបការអីអោយយើង នឹងហាស

ក៖ ប៉ុន្តែឪពុកម្តាយរបស់មីងនឹងកាលណុងគាត់នៅណាដែរទៅ?

ខ៖ ពេលណុងនៅឆ្ងាយហើយទាល់តែគេថាបែកហើយនឹង
បានរត់រកកូននឹងហើយកូនរត់រកម៉ែចឹងទៅ
បានជុំគ្នានឹងក៏បានដើរតាំងពីពោសាត់បាត់ដំបងនឹងរហូតមកដល់នឹងទៅ

ក៖ អុំ!!បងប្អូនរបស់មីងនឹងក៏នៅបែកពីឪពុកម្តាយដែរ?

ខ៖ បែកទាំងអស់នឹងដល់ពេលហើយចឹងទៅបានមកជុំគ្នា

ក៖
មកជុំគ្នាប៉ុន្តែយើងធ្វើម៉េចបានដឹងថាជុំគ្នាឪពុកម្តាយវិញដោយសារតែពេលណុងអត់មានទូរស្ទ័អីផង នឹងមីង?

ខ៖ អត់ប៉ុន្តែកងអីវ៉ាន់មេប្រធានខ្ញុំនឹងដើររកមួយទីក្រុងពោសាត់នឹង

ក៖ ដើររកឪពុកម្តាយទៅ?

ខ៖
ដើររកស្រាវជ្រាវថាអូនកុមារឯងនឹងស្គាល់ឈ្មោះម៉ែដែរទេយើងថាស្គាល់ដល់ពេលថាស្គាល់ចឹងទៅ
គាត់ដើរជាង10នាក់ចឹងទៅដើរជយបឪពុកម្តាយណាហុចអោយកូនទៅឪពុកម្តាយគេទៅហើយក៏ទៅទៀតទៅនឹងដើរស្រាវជ្រាវហាសមេកងនឹង

ក៖ រហូតទាល់តែជួបឪពុកម្តាយនឹងវិញទៅ?

ខ៖ ចា៎!!មេកងនឹងឈ្មោះពូហោៗៗនឹងហាស

ក៖ បាទមីងបាទ?

ខ៖
នឹងហើយគាត់ល្អដែរនឹងដើររកបើកុំតែគាត់ដើររកនឹងបងប្អូនកាលណុងនៅតូចៗៗនឹងកងអឺវ៉ាន់ នឹងគ្មានទេស្រួលនឹងព្រាតព្រាស់អស់ហើយនឹង

ក៖ អត់ដឹងទេណាមីង?

ខ៖ ចា៎!!នឹងហើយអត់ស្គាល់ស្រុកទេកាលពីជំនាន់ណុងហោស

ក៖ ចុះពេលដែរដាច់ពលពតនឹងមីងធ្វើអីគេដែរទៅមីងពេលណុង?

ខ៖ ជំនាន់ពលពតមកដល់ដើរធ្វើសំណាង់អីចឹងទៅយកមកចិញ្ចឹមជីវិតចឹងទៅណាស់

ក៖ ប៉ុន្តែកាលដាច់ជំនាន់ពលពតនឹងគេហៅជំនាន់ខ្មែរក្រហមហីមីង?

ខ៖ ជំនាន់ខ្មែរក្រហមនឹង

ក៖ ប៉ុន្តែមីងមានបញ្ហាអីកើតឡើងទៅពេលណុងមីង?

ខ៖ អត់ដឹងទេអូនដឹងតែវាបង្អត់យើងធ្វើបាបយើងអត់អោយយើងហូបនឹង

ក៖ ខ្មែរក្រហមនឹងហោសមីង?

ខ៖ ខ្មែរក្រហមនឹងហាស

ក៖ រួមចឹងយើងពិបាកមួយទៀតហើយណាមីង?

ខ៖  ចា៎!!អូពិបាកណាស់អូនអត់ដែរមានស្គាល់អង្ករយ៉ាងម៉េចទេនឹង ស្គាល់តែដំឡូងឈើនឹងទងដំឡូងជ្វា ហើយនឹងត្រកួននឹងហើយកន្ទួក មិនដែរបានស្គាល់ជាតិបាយ សូម្បីតែបបរមួយខ្ទះយើងត្នោតនឹងមាន អង្ករមួយកំប៉ុងគ្នាមាន30នាក់ជាងនឹង

ក៖  និយាយរួមនឹងពិបាករហូតតែម្តងនឹងមីង?

ខ៖  ពិបាករហូតនឹងអូនអើយវេទនាណាស់

ក៖  ចុះរហូតដល់ពេលណាដែរមីងគិតថាស្រួលហាសមីង មីងគិតថាស្រួលហើយមីងលែងសូវពិបាក រឿងអីចឹងហាស?

ខ៖  ទើបតែមកឥឡូវនឹងទេអូនវាមានដូចថាយើងមានហូបគ្រប់គ្រាន់យើងមានសេរីភាព

ក៖  បាទៗចង់និយាយចឹងហាសមីង?

ខ៖  ចា៎!!ចង់យើងធ្វើអីក៏បានដែរនឹងហាសណាស់

ក៖  បាទមីងត្រូវនឹង?

ខ៖  វាគ្រាន់បើជាងជំនាន់អាពតនឹង វាគ្រាន់បើជាងជំនាន់លុនណុលរត់លូនៗនឹង ខ្ញុំអត់ចេះអក្សរដោយ សារតែស្អីអូនដោយសារតែរត់លូនៗនឹងហាសអូនអើយ

ក៖  អូ៎!បាទមីងបាទ?

ខ៖

ទើបតែមកជំនាន់អាពតនឹងតើគេអោយរៀនអាក់ករៈកម្មនឹងបានចេះប្រកបចឹងទៅចេះមើលឈ្មោះ ចរមើលអីដាច់ចឹងទៅ បានមានប្តីចឹងទៅ

ក៖  កាលពីរៀនអាក់ករៈកម្មនឹងនរណាគេជាអ្នកបង្រៀនដែរមីង?

ខ៖  ប្រធានភូមិឃុំនឹងហាសគេរើសអ្នកអត់ចេះអក្សរៗកុមារចឹងហាស

ក៖  ប៉ុន្តែមីងសុំសួរបន្តិចគេថាបើមានអ្នកចេះដឹងគេនឹងយកទៅរៀនសូត្រ ប៉ុន្តែចុះម៉េចបានគេអោយ យើងរៀនដែរមីង?

ខ៖  អត់ទេណុងជំនាន់អាពតហាស

កៈ ពេលដែររៀនអាក់ករៈកម្មនឹងចប់ហើយមែនទេមីង?

ខៈ ចប់ហើយនឹង

កៈ ចឹងចប់ពលពតនឹងហើយហោសមីង?

ខៈ ចប់ពលពតនឹងហើយប្រធានភូមិ
នឹងប្រធានឃុំរើសនរណាគេដែរមិនចេះអក្សរនឹងអោយរៀនចឹងទៅ
អោយរៀនអាក់ករៈកម្មចឹងទៅដើម្បីអោយចេះអក្សរចឹងទៅ

កៈ ចុះយើងអត់មានជាសាលាទេណាមីង បានគេអោយរៀនអាក់ករៈកម្មចឹងហាសមីង?

ខៈ រៀនតាមទីស្នាក់ការកាលពីជំនាន់ណុង

កៈ ប៉ុន្តែមិនទាន់មានសាលាបើកទេនឹង?

ខៈ អត់ទាន់មានទេ

កៈ
ចុះមីងគិតថាកាលលំបាកដែរមីងបានជួបនឹងតើមីងគិតថាមានការលំបាកដោយរបៀបណាដែរមីង?

ខៈ ឆ្លងកាត់និយាយរួមទៅមកពីសង្គមនឹង
សង្គមកាលណុងសង្គមវេទនានឹងហាសសង្គមហាត់លិតតែ ម្តងនឹង

កៈ អ៊ូ!បាទត្រូវហើយមីង?

ខៈ ចា៎!!បើសង្គមនេះគ្រាន់បើនឹង

កៈ
ចុះមីងគិតថាពេលណាដែរមីងគិតថាជាពេលដែរសប្បាយរបស់មីងដែរកាលពីក្មេងរហូតមកដល់ ពេលនេះហាសមីង?

ខៈ គិតមើលទៅអត់មានទេអូន

កៈ ចុះពេលដែរការកូននឹងការខ្លួនឯងនឹងមីងគិតថាសប្បាយទេ?

ខៈ ការខ្លួនឯងនឹងសប្បាយ មកការខ្លួនឯងនឹងក៏សប្បាយដែរនឹង

កះ ប៉ុន្តែសប្បាយមួយភ្លេតទេណាមីង?

ខះ សប្បាយមួយភ្លេតនឹងកើតទុកនឹងរឿងរកស៊ីនឹងអត់នឹងតែម្តងនឹងអូន
មិនដែរមានពេលបានសំរាក នឹងអង្គុយយ៉ាងម៉េចទេខ្ញុំ

កះ អូ៎!បាទមីងបាទ?

ខះ និយាយទៅនិយាយមើលទៅយើងអ្នកអត់ហាស

កះ បាទមីងបាទ?

ខះ គេអ្នកមាននឹងគេសប្បាយរហូតនឹងយើងអ្នកអត់នឹង

កះ ចឹងយើងតែងតែមានបញ្ហាហើយណាមីង?

ខះ តែងតែមានបញ្ហាហើយនឹងអូនអើយ

កះ
ចុះមីងគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះនឹងមីងធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹង មីងចង់ធ្វើអីដែរទេមីង?

ខះ អត់មានទេ

កះ ចុះកាលពីមីងនៅក្មេងនៅរៀននឹងមីងគិតថាមីងចង់ធ្វើជាគ្រូ ចង់ធ្វើជាប៉ូលីស
រឺមួយក៏គ្រូពេទ្យអីទេមីង?

ខះ ចង់បានវាចង់ហើយចង់ជាពិសេសជាងគេនឹងធ្វើគ្រូនឹងអូន
ប៉ុន្តែមកពីយើងមិនចេះតំរិះវិជ្ជានឹងហាស ចឹងយើងធ្វើម៉េចកើតទៅ

កះ អូ៎!បាទមីងបាទ?

ខះ មកពីយើផងរត់លួនៗៗនឹងអត់ចេះផង ប៉ុន្តែស្រម៉ៃដឹងតែចង់ធ្វើជាគ្រូបង្រៀនចឹង

កះ មីងស្រម៉ៃចង់ធ្វើជាគ្រូបង្រៀន?

ខះ ចង់ធ្វើដែរប៉ុន្តែគ្រាន់តែថា

កះ វាទៅមិនរួចណាមីង?

ខ៖ អំណោយផងមិនហុចអោយយើងហាស

ក៖ បាទមីងបាទ
ចុះបើសិនជាចង់អោយមីងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗៗនឹងតើមីងចង់ផ្តែផ្តាំអីទៅពួកគាត់ដែរមីង?

ខ៖
ខ្ញុំចង់ផ្តែផ្តាំថាចង់អោយក្មេងៗៗស្គរកក្រោយនឹងខំរៀនសូត្រចេះដឹងតំរិះខ្លួនយើងនឹងមិនអាច មាននរណាគេលួចបានទេ

ក៖ បាទមីងបាទ?

ខ៖ ធ្វើម៉េចទេជំនាន់ខ្ញុំនឹងវាល្ងង់នឹងខ្ញុំស្តាយហាសអូន

ក៖ បាទមីងបាទ?

ខ៖ ហើយមិនបានរៀនសូត្រអីមិនបានជិតដល់ចឹងហាស

ក៖
ចុះមីងគិតថាមីងចង់អោយពួកគាត់នឹងរៀនទៅដើម្បីចង់អោយពួកគាត់យកទៅធ្វើអីគេដែរមីង?

ខ៖ ដើម្បីអោយតែរៀនចេះទៅនឹងសង្គមនឹងវាចង់ធ្វើជាគ្រូពេទ្យស្រេចតែដុងរបស់វាចឹង

ក៖ នៅពេលដែរយើងចេះទៅមិនសូវខ្វះការងារធ្វើទេណាមីង?

ខ៖
ចាំ!!ដូចចៅរបស់ខ្ញុំរាល់ថ្ងៃចឹងចង់រៀនណាស់ប៉ុន្តែឪពុកម្តាយវានឹងមិនមានលុយអោយកូនរៀន

ក៖ ម៉េចចឹងមីង?

ខ៖ អត់

ក៖
ដោយសារតែក្មេងៗៗនឹងគេរៀននៅសាលាបឋមនឹងរៀនមិនសូវអស់លុយច្រើនផងនឹងមីង?

ខ៖ អត់ចេះណាស់ចៅរបស់ខ្ញុំនឹងរៀនពូកែតែម្តងនឹងនិយាយរួមទៅ

ក៖ បាទមីងបាទ?

ខ៖ ប៉ុន្តែគ្រាន់ថាវាដូចថាម្តាយឪពុកនឹងវាអត់ចឹងហាស

ក៖ បាទមីងបាទ?

ខ៖ ចា៎!!នឹង

ក៖
ចុះមីងបើសិនជាចង់អោយពួកគាត់ជៀសវៀងវិញតើមីងចង់អោយពួកគាត់ជៀសវៀងអីគេដែរវិញ មីងចឹង?

ខ៖
ខ្ញុំនឹងចង់អោយពួកគេជៀសវៀងជាពិសេសជាងគេនឹងថ្នាំញៀននៅស្រុកខ្មែរយើងនឹងអូន

ក៖ ដោយសារតែមានបញ្ហាច្រើនដែរទាក់ទងនឹងថ្នាំញៀនមែនទេមីង?

ខ៖
ចា៎!!ទៅក្នុងមណ្ឌលនៅពន្ធធនាគារអូនអើយទៅសួរម៉ាត់ណាញៀនទាំងអស់នឹងសួរៗអូនឯងនឹង ញៀនទាំងអស់នឹង

ក៖ អូ៎!បាទមីងបាទ?

ខ៖
ចឹងបានថាខ្ញុំនៅសង្គមនេះនឹងខ្ញុំបើវាជៀសឆ្ងាយធ្វើម៉េចអោយតែបាត់សង្គមផុតពីថ្នាំញៀននឹងខ្ញុំ នឹងអរគុណហើយនឹង

ក៖ បាទមីង?

ខ៖ សឹងតែថាលួនពីនឹងទៅដល់ថ្នល់ហោស

ក៖ អូ៎!ចឹងហោសមីង?

ខ៖ ពីព្រោះអីនឹងខ្ញុំវាផុតហើយនឹងប៉ុន្តែកូនរបស់ខ្ញុំនឹងចៅរ
បស់ខ្ញុំនឹងអនាគត់បើចឹងទេស្លាប់ហើយនឹង

កៈ  អូ៎!ខ្លាចពួកគាត់មានបញ្ហាខាងគ្រឿងញៀនណាមីង?

ខៈ  ចាំ!!ពីព្រោះកូនរបស់ខ្ញុំចូលពន្ធធនាគារមួយហើយនឹង

កៈ  អូ៎!ចឹងហោស ចឹងមានន័យថាគាត់នឹងប្រើគ្រឿងញៀនដែរហោសមីង?

ខៈ  អត់ប្រើប្រាស់ទេសង្គមនឹងដូចថាគេរបៀបដូចថាគេចោទប្រកាន់និយាយរួមទៅអូន

កៈ  អូ៎!!ចឹងហោសមីង?

ខៈ  អត់ទេនឹង

កៈ  ប៉ុន្តែគេចោទគាត់?

ខៈ  គេជ្រុះកាបូបចឹងទៅវារើសចឹងទៅគេចោទនឹង
គេស្រែកថាចោរនឹងគេវៃកូនរបស់ខ្ញុំនឹងជិតស្លាប់
ហើយដល់ពៅគេពីមុននឹងវានៅជាមួយខ្ញុំនឹង

កៈ  បាទមីងបាទ?

ខៈ
ដល់ឥឡូវនឹងគេយកទៅជាប់គុកពីរឆ្នាំនឹងវាយំចង់ចេញរហូតនឹងប៉ុន្តែមិនដឹងថាចេញតាមច្រកណា ទេនឹង

កៈ  អូ៎!!បាទមីងបាទ ចុះចឹងមីងមានអីចង់ផ្ដែផ្ដាំផ្សេងទៀតទេមីង?

ខៈ  ចង់ផ្ដែផ្ដាំថាសង្គមនឹងកុំអោយថាកូនជៀសវៀងពីប្ដីនឹងពីគ្រឿងញៀននឹង
សង្គមគេស្អប់ខ្ពើមនឹង ចង់អោយវាជៀសអោយឆ្ងាយនឹង

កៈ  បាទមីងបាទនឹង?

ខៈ  ខ្ញុំមើលទៅពិបាកណាស់រាល់ថ្ងៃនឹង

កៈ  បាទមីងពិបាកមែន?

ខៈ  ម៉ែឪនឹងយំស្រែកជក់នឹងអូន ជក់លក់ជួញនឹងៗៗ

កៈ  អូ៎!បាទមីងបាទ?

ខ៖ ឆ្ងួតអស់ហើយនឹងស្រុកខ្មែរយើងនឹង

ក៖ មានបញ្ហាមួយនឹងច្រើនសំរាប់សង្គមខ្មែរណាមីង?

ខ៖ វេទនាណាស់

ក៖ បាទមីងបាទ?

ខ៖ នឹងមកពីសង្គមទេអូន
មិនមែនមកពីឪពុកម្ដាយប្រដៅមិនដល់ទេមកពីសង្គមនឹងតែម្ដងនឹង

ក៖ បាទមីងបាទ?

ខ៖ បើសង្គមនឹងវាមិនបង្កើតនឹងក៏សង្គមនឹងវាមិនពិបាកដល់ម្លឹងដែរនឹង

ក៖ បាទមីងចឹងជាចុងក្រោយខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំពិភាក្សាពីប្រវត្តិរបស់មីង
ចឹងហាសមីង?

ខ៖ ចា៎!!!

ក៖ ចឹងអរគុណច្រើនមីង៕៕៕